# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៥...សសរ

## សេចក្ដីសំរេច

## ស្ដីពីការបង្កើតគណៈកម្មការដើម្បីរៀបចំខ្លឹមសារ សំរាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៣

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការដើម្បីរៀបចំខ្លឹមសារសំរាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី ៣ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **នីយ រឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| ៣- ឯកឧត្តម **សៀង ឡាប្រេស្ស** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **សក់ សេដ្ឋា** | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- **តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | | សមាជិក |
| ៦- លោក **ជាង ឡេងហួត** | អគ្គនាយករងរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៧- លោកឧត្តមសេនីយ៍ទោ **មៀច សុផាន់ណា** | ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៨- លោកឧត្តមសេនីយ៍ត្រី **គៀត ចន្ទថារិទ្ធ** | ប្រធានសេនាធិការដ្ឋាន នៃអគ្គស្នងការនគរបាលជាតិ | សមាជិក |

www.pheakdeylaw.com

៩- លោក ខាំពួន កែវមុនី អ្នកបកប្រែ

**ប្រការ ២.-**

គណៈកម្មការខាងលើនេះមានតួនាទី ភារកិច្ច និងសិទ្ធិអំណាចដូចខាងក្រោម ÷

- សម្របសម្រួលជាមួយក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំខ្លឹមសារសំរាប់គណៈប្រតិភូ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមក្នុងកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី ៣ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកលើខ្លឹមសារដែលបានសម្របសម្រួលខាងលើនេះ ដើម្បីពិភាក្សាជាមួយភាគីថៃ សហការរៀបចំខ្លឹមសារប្រជុំឱ្យបានសមស្រប
- ប្រធានគណៈកម្មការត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គណៈកម្មការមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងពិភាក្សាការងារសំរាប់ត្រៀមរៀបចំការប្រជុំនេះ តាមការចាំបាច់
- អនុប្រធាន និងសមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និងទទួលភារកិច្ចតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ
- គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃ ក្នុងការចាត់ចែងការងាររបស់ខ្លួន ។

**ប្រការ ៣.-**

គណៈកម្មការត្រូវបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី ៣ ត្រូវបានបញ្ចប់រួចរាល់ និងបន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម អស់លោកដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com